# 1 វិធីបន្ការកុំឲ្យមានផ្ទៃពោះ : ជំរើសរបស់អ្នក
# (1. Contraception: Your Choices)

## ហេតុអ្វីបានជាប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ?

**ការបង្ការមិនឲ្យមានផ្ទៃពោះ គឺជាការចាំបាច់ បើអ្នកចង់ចៀសវាងផ្ទៃពោះដែលមិនចង់បាន និងជំងឺកាមរោគ។**

រៀងរាល់ខែ អូវែររបស់ស្ត្រីផលិតពងមេជីវិតស្ត្រី។ នៅពេលដែលបុរសបញ្ចេញទឹកកាម  ទឹកកាមនេះមានមេជីវិតបុរសរាប់លាន។ វាត្រូវការតែមេជីវិតបុរសនេះមួយប៉ុណ្ណោះ ដើម្បីចូលទៅបង្កាត់ក្នុងពងមេជីវិតស្ត្រី ហើយចាប់ផ្តើមមានផ្ទៃពោះ។ បើគូស្រករធ្វើការរួមរ័កនឹងគ្នា (លិង្គនៅក្នុងរន្ធយោនី) ហើយគ្មានការប្រុងប្រយ័ត្នជាមុនទេនោះ ស្ត្រីមានលទ្ធភាពខ្ពស់ក្នុងការមានផ្ទៃពោះ។ ការប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះ អនុញ្ញាតឲ្យអ្នករួមរ័ក ហើយចៀសវាងការមានផ្ទៃពោះដោយអចេតនា។

## ស្រោមអនាម័យ មិនមែនជាគំនិតល្អជានិច្ចឡើយ

ប្រទេសអូស្ត្រាលី មានជំងឺកាមរោគថ្មីជាង 20 000 ក្នុងមួយឆ្នាំៗ។ ជំងឺកាមរោគទូទៅបំផុតគឺ chlamydia ដែលអាចធ្វើឲ្យមិនអាចមានកូនបាន បើទុកចោលមិនព្យាបាលទេនោះ។ ស្រោមអនាម័យគឺជាការការពារប្រសើរ បំផុតរបស់អ្នកទល់នឹងជំងឺកាមរោគ។ បើអ្នកប្រើស្រោមអនាម័យនិងប្រេងរំអិលធ្វើពីជាតិទឹក នៅរាល់ពេលដែលអ្នករួមភេទ  អ្នកនឹងមានឱកាសតិចក្នុងការឆ្លង HIV/AIDS និងជំងឺកាមរោគ (STIs) ជាច្រើនទៀត។

## ការជ្រើសរើសវិធីបង្ការកុំឲ្យមានផ្ទៃពោះរបស់អ្នក

អ្នក និង វេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកសុខភាពស្ត្រីរបស់អ្នក អាចនិយាយអំពីវិធីប្រសើរបំផុតដើម្បីបង្ការកុំឲ្យអ្នកមានផ្ទៃពោះ។

**ពត៌មានតទៅនេះ គឺជាសេចក្តីពណ៌នាដោយសង្ខេបអំពីជំរើសរបស់អ្នក នូវវិធីបង្ការកុំឲ្យមានផ្ទៃពោះ។** បើអ្នកចង់បានពត៌មានបន្ថែមអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះជាក់លាក់មួយ សូមសាកសួរវេជ្ជបណ្ឌិតឬឱ្សថរបស់អ្នក។ ឬមួយអ្នកអាចរកឃើញប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះនិងពត៌មានផ្សេងទៀតរបស់យើង នៅតាមវ៉ិបសៃផ្សព្វផ្សាយសុខភាពរបស់យើង គឺ :

**http://wellwomens.rwh.org.au.**

## ស្រោមអនាម័យរបស់ស្ត្រី

ស្រោមអនាម័យរបស់ស្ត្រី មានប្រសិទ្ធភាពណាស់នៅពេលប្រើត្រឹមត្រូវ។ ស្រោមនេះគឺជាបន្ទះស្រោមមានលាបប្រេងរំអិលជាមុន ដែលដាក់ចូលយ៉ាងជួររលុងទៅខាងក្នុងរន្ធយោនី ហើយអាចដកចេញដោយងាយនៅពេលក្រោយមក។ នេះមានន័យថា អ្នកត្រូវប្រើស្រោមថ្មីមួយ នៅរាល់ពេលដែលអ្នករួមភេទ។

ស្រោមនេះពុំមានផលវិបាកទេ ហើយកាត់បន្ថយលទ្ធភាពក្នុងការឆ្លងជំងឺកាមរោគ។ យ៉ាងណាមិញ ស្រោមនេះថ្លៃគួរសមដែរ ហើយលំបាកនឹងរកទិញវាណាស់។

**សូមអានផងដែរនូវប័ណ្ណពត៌មានទី 2 *ស្រោមអនាម័យ***

## ស្រោមអនាម័យបុរស

ស្រោមអនាម័យបុរស គឺជាស្រោមបន្ទះកៅស៊ូ ឬជាតិ polyurethane ដែលពាក់នៅលើលិង្គឡើងរឹង។ ស្រោមនេះប្រមូលយកទឹកកាមបុរស ហើយបញ្ឈប់កុំឲ្យទឹកកាមនេះចូលទៅក្នុងរន្ធយោនី និង ស្បូន។ អ្នកអាចទិញស្រោមនេះដោយងាយពីឱសថស្ថាន និង ហាងលក់ទំនិញចំរុះ។ ស្រោមនេះកាត់បន្ថយលទ្ធភាពនៃការមានផ្ទៃពោះ និង ជំងឺកាមរោគ។

**សូមអានផងដែរនូវប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះ ទី 2 ស្រោមអនាម័យ និង ស្រោម Diaphragms**

## ស្រោម Diaphragms

ស្រោមនេះ គឺជាគំរបកៅស៊ូទន់ដែលពាក់នៅខាងក្នុងរន្ធយោនី ដើម្បីគ្របកស្បូន (ផ្លូវចូលទៅក្នុងស្បូន)។ ស្រោមនេះបង្ការមិនឲ្យទឹកកាមបុរសចូលទៅក្នុងស្បូន។ អ្នកអាចប្រើស្រោមនេះនៅគ្រប់ពេលទាំងអស់ ទោះជាក្នុងអម្លុងពេលមានរដូវក៏ដោយ ហើយអាចលាងសម្អាតនិងប្រើម្តងហើយម្តងទៀត។ អ្នកត្រូវដាក់ស្រោមនេះ មុនពេលរួមភេទ (រហូតដល់ទៅ 24 ម៉ោងជាមុន) ហើយដកយកវាចេញនៅក្រោយពេលប្រាំមួយម៉ោង។ ស្ត្រីខ្លះយល់ថា គេមានការលំបាកនឹងស៊ិកបញ្ចូលវា។

**សូមអានផងដែរនូវប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះ ទី 2 ស្រោមអនាម័យ និង ស្រោម Diaphragms**

## Pill (ថ្នាំគ្រាប់)

ថ្នាំគ្រាប់សំរាប់លេបបង្ការកុំឲ្យមានផ្ទៃពោះ មានប្រភេទចំបងពីរយ៉ាង។

***ថ្នាំគ្រាប់គួបផ្សំ***

មានអ័រម៉ូនពីរ ហើយបញ្ឈប់មិនឲ្យអូវ៉ែរបញ្ចេញពងមេជីវិតស្ត្រី ជារៀងរាល់ខែ។ អ្នកនៅតែធ្លាក់ឈាមរៀងរាល់ខែ ប៉ុន្តែជាញឹកញយ ធ្លាក់ឈាមកាន់តែតិចទៅ។ ថ្នាំគ្រាប់គួបផ្សំនេះ អាចកែលំអរោគសញ្ញានៃការកើតមុន និងរោគសញ្ញាមុនពេលមានរដូវ។ ផលវិបាកម្តងម្កាល មានរួមទាំងហើមពោះ ចង្អោរ និង ឡើងទម្ងន់។

***ថ្នាំគ្រាប់មានតែ progestogen ប៉ុណ្ណោះ (minipill ឬ POP)***

មានអ័រម៉ូនតែមួយ ហើយសំដែងមុខងារដោយកែប្រែទឹករំអិលនៅនឹងច្រកចូលទៅកាន់ស្បូន ដើម្បីកុំឲ្យមេជីវិតបុរសអាចឆ្លងកាត់ទៅបង្កាត់ជាមួយនឹងពងមេជីវិតស្ត្រី។

ថ្នាំគ្រាប់មានតែ progestogen ប៉ុណ្ណោះ មានប្រសិទ្ធភាពតិចជាងថ្នាំគ្រាប់គួបផ្សំ ដោយសារតែវាមិនអាចបញ្ឈប់ការបញ្ចេញពងមេជីវិតស្ត្រីបានទេ។

**សូមអានផងដែរនូវប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះទី 3 – *Pill (ថ្នាំគ្រាប់)***

***Emergency Pill (ថ្នាំគ្រាប់គ្រាអាសន្ន)***

**(ស្គាល់កាលគ្រាមុនថា Morning After Pill [ថ្នាំគ្រាប់នៅពេលព្រឹកបន្ទាប់])**

បើអ្នកមិនប្រើវិធីបង្ការកុំឲ្យមានផ្ទៃពោះទេ ហើយអ្នកបានរួមភេទនៅពេលដែលអ្នកមិនបានគ្រោងទុក ឬ រហែកស្រោមអនាម័យ ហើយអ្នកមិនចង់មានផ្ទៃពោះ នោះអ្នកអាចលេបថ្នាំគ្រាប់គ្រាអាសន្ន។ អ្នកអាចទិញថ្នាំគ្រាប់ គ្រាអាសន្ននេះពីឱសថស្ថាន ដោយមិនចាំបាច់មានវេជ្ជបញ្ជាឡើយ។

ត្រូវចាប់ផ្តើមប្រើថ្នាំគ្រាប់គ្រាអាសន្ន ក្នុងរង្វង់ពេលបីថ្ងៃ (72 ម៉ោង) ក្រោយពីរួមភេទដោយគ្មានការពារហើយ។

***សូមអានផងដែរនូវប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះទី 3 – Pill (ថ្នាំគ្រាប់)***

## ការចាក់ថ្នាំបង្ការកុំឲ្យមានផ្ទៃពោះ

DMPA (ហៅផងដែរថា Depo Provera ឬ Depo Ralovera) គឺជាថ្នាំចាក់ឲ្យស្ត្រីនៅពេល 12 អាទិត្យម្តងសំរាប់បង្ការកុំឲ្យមានផ្ទៃពោះ។ វាជាអ័រម៉ូនសាំងតេទិកធ្វើសកម្មភាពរយៈពេលយូរ។ គេអាចប្រើថ្នាំនេះនៅពេលស្ត្រីឲ្យកូនបៅដោះ។ ផលវិបាកណាមួយដែលកើតមានឡើង អាចមានរយៈពេលដល់ទៅ 12 អាទិត្យ។

**សូមអានផងដែរនូវ**

**ប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះទី 4 – *ការចាក់ថ្នាំ និង ការវះផ្សាំ***
**ប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះទី 5 – *ថ្នាំ Depo Provera***

## ការវះស្បែកដាក់ថ្នាំបង្ការកុំឲ្យមានផ្ទៃពោះ

នេះជាបង្កង់ប្លាស្ទិកតូចមានអ័រម៉ូនមួយគឺ progestogen ដែលត្រូវបានស៊កបញ្ចូលនៅក្រោមស្បែករបស់ស្ត្រី នៅនឹងផ្នែកខាងក្នុងនៃដើមដៃ។ ថ្នាំនេះបញ្ឈប់កុំឲ្យអូវែរបញ្ចេញពងមេជីវិតស្ត្រីនៅខែនីមួយៗ។ ស្ត្រីភាគច្រើនមានលំនាំធ្លាក់ឈាមផ្សេងគ្នា ហើយស្ត្រីខ្លះឈប់ធ្លាក់ឈាមទាំងស្រុង។ ស្ត្រីខ្លះឈឺដោះ ឈឺក្បាល ឬ វិលមុខ។

***សូមអានផងដែរប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះទី 4 – ការចាក់ថ្នាំ និង ការវះផ្សាំ***

## ឧបករណ៍ដាក់ក្នុងស្បូន (IUD)

នេះជាឧបករណ៍តូចមួយសំរាប់បង្ការកុំឲ្យមានផ្ទៃពោះ ដែលដាក់នៅក្នុងស្បូនរបស់ស្ត្រី។ ឧបករណ៍នេះមានពីរប្រភេទ គឺ IUD ទង់ដែង និង Progestogen IUD ឬ Mirena IUD ។

ទោះជាគេបានប្រើ IUD អស់ពេលជាង 30 ឆ្នាំមកហើយដើម្បីបង្ការកុំឲ្យមានផ្ទៃពោះក្តី ក៏គេនៅតែមិនយល់ពេញលេញនូវរបៀបចំពេញមុខងាររបស់វានៅឡើយដែរ។ IUD មានផលប៉ះពាល់ដល់ចលនានិងការរស់រានមានជីវិតរបស់មេជីវិតបុរសនៅក្នុងស្បូន ដើម្បីកុំឲ្យមេជីវិតបុរសអាចធ្វើដំណើរទៅបង្កាត់ពងមេជីវិតស្ត្រី។ IUD ក៏ផ្លាស់ប្តូរស្រទាប់ក្នុងនៃស្បូន (endometrium) ផងដែរ ដើម្បីកុំឲ្យស្បូនសក្តិសមនឹងមានផ្ទៃពោះ ហើយបង្ការកុំឲ្យពងមេជីវិតស្ត្រី – បើសិនជាបានបង្កាត់ជាមួយមេជីវិតបុរសហើយនោះ – រីកចំរើនលូតលាស់ទៅជាទារកបាន។

វាជាវិធីបង្ការកុំឲ្យមានផ្ទៃពោះរយៈពេលយូរ ដែលមានប្រសិទ្ធភាពណាស់។

IUD ទង់ដែង អាចបណ្តាលឲ្យរដូវរបស់អ្នកមានច្រើនជាងមុន ហើយ Mirena IUD (ដែលមាន Protestogen) នឹងកាត់បន្ថយការធ្លាក់ឈាមរបស់អ្នក។

## ការបំបាត់ភាពបន្តពូជ (ស្តេរីល)

ទាំងបុរសនិងទាំងស្ត្រី អាចធ្វើការវះកាត់ដើម្បីឲ្យខ្លួនមិនអាចបន្តពូជតទៅទៀតបាន។ ប្រតិបត្តិការវះកាត់របស់ស្ត្រី ត្រូវបានធ្វើតាមរយៈពោះ ហើយត្រូវបានហៅថា ការបង្ខាំងបំពង់ ហើយការវះកាត់របស់បុរសត្រូវបានហៅថា ការកាត់ផ្តាច់បំពង់មេជីវិត។ ការវះកាត់នេះ មានប្រសិទ្ធភាពជាង 99% ហើយមានលក្ខណៈអចិន្ត្រៃយ៍។ វិធីនេះ គឺសំរាប់អ្នកដែលមានកូនដែលខ្លួនចង់បានរួចទៅហើយ។

ឥឡូវនេះ គេមានបំពង់ស៊ីកតូចឆ្មារដែលអាចដាក់ទៅក្នុងបំពង់របស់ស្ត្រី តាមរយៈឧបករណ៍ពិសេស។ ទំរង់ការនេះ ត្រូវបានធ្វើតាមរយៈរន្ធយោនី ហើយអាចធ្វើទៅនៅក្នុងពេលដែលស្ត្រីភ្ញាក់ដឹងស្មារតី។

## វិធីធម្មជាតិនៃការបង្ការកុំឲ្យមានផ្ទៃពោះ

**វិធីនៅខាងក្រោមនេះ ពុំមានប្រសិទ្ធភាពខ្លាំងទេ ហើយជាធម្មតា មិនគួរប្រើវាតែឯង ជាវិធីបង្ការកុំឲ្យមានផ្ទៃពោះនោះឡើយ។**

វិធីចង្វាក់, Billings, ទឹករំអិល, ការបញ្ចេញពងមេជីវិតស្ត្រី និង សីតុណ្ហភាព គឺជាឈ្មោះនៃរបៀបដែលស្ត្រីអាចប្រាប់ពេលដែលខ្លួនអាចមានផ្ទៃពោះបាន (ទំនងបំផុតក្នុងការមានផ្ទៃពោះ)។ វិធីទាំងនេះប្រាប់ស្ត្រីនូវពេលដែលត្រូវចៀសវាងការរួមភេទ។ បើរដូវរបស់ស្ត្រីពុំមានភាពទៀងទាត់ទេ ការប្រើវិធីទាំងនេះអាចលំបាកណាស់។ វិធីទាំងនេះ តម្រូវឲ្យមានការហាត់អនុវត្តច្រើន ដើម្បីប្រើឲ្យបានល្អ ហើយប្រហែលជាពុំសំរេចជោគជ័យទេ។

*ការដកចេញ*

នេះជាពេលដែលបុរសដកលិង្គចេញពីរន្ធយោនី មុនពេលបញ្ចេញទឹកកាម។ វិធីនេះគ្មានប្រសិទ្ធភាពទេ បើបុរសភ្លេចដកលិង្គចេញ ឬ ដកមិនទាន់ពេល។ មេជីវិតបុរសខ្លះក៏អាចស្ថិតនៅក្នុងទឹករំអិលមុនចេញទឹកកាមផងដែរ (ទឹករំអិលដែលចេញពីលិង្គនៅមុនពេលចេញទឹកកាម)។ បើបុរសចេញទឹកកាមនៅនឹងផ្លូវទ្វារចូលនៃរន្ធយោនី មេជីវិតបុរសខ្លះ នៅតែអាចហែលនៅខាងក្នុង ហើយស្ត្រីនៅតែអាចមានផ្ទៃពោះដោយសារតែវិធីនេះដែរ។

*ថ្នាំសម្លាប់មេជីវិតបុរស*

នេះជាប្រេងអន្ទិល ឬ ប្រេង ដែលដាក់បញ្ចូលនៅខាងក្នុងរន្ធយោនី មុនពេលអ្នករួមភេទ។ អ្នកខ្លះប្រើថ្នាំសម្លាប់មេជីវិតបុរស ព្រមជាមួយស្រោមអនាម័យ ឬ ស្រោម diaphragm ប៉ុន្តែថ្នាំនេះគ្មានប្រសិទ្ធភាពទេ បើប្រើតែឯងនោះ។

## ទីកន្លែងទទួលពត៌មានបន្ថែម

**Women’s Health Information Centre (RWH)**
(03) 8345 3045
1800 442 007 (ទូរស័ព្ទឥតគិតថ្លៃ) អ៊ីមែល : whic@thewomens.org.au
http://www.thewomens.org.au

**The Choices Clinic នៅឯ Royal Women's Hospital**

ជាកិច្ចបំរើគិតថ្លៃថោក ដែលផ្តល់ឱវាទ ការពិគ្រោះឱវាទ និង ការព្យាបាលសំរាប់តម្រូវការបង្ការកុំឲ្យមានផ្ទៃពោះ និងសុខភាពផ្លូវភេទទាំងអស់។
ពេលម៉ោង : ថ្ងៃច័ន្ទ អង្គារ ព្រហស្បតិ៍ ម៉ោង 8.30 ព្រឹក ដល់ម៉ោង 11.30 ព្រឹក។
ទូរស័ព្ទ : (03) 8345 2000

## ប័ណ្ណពត៌មានឯទៀតដែលអាចមានប្រយោជន៍សំរាប់អ្នក

RWH មានប័ណ្ណពត៌មានផ្សេងៗជាភាសាច្រើន នៅតាមអ៊ីនធើរណិត។ បើអ្នកចង់បានពត៌មានបន្ថែម អ្នកអាចបើកមើលវិបសៃផ្សព្វផ្សាយសុខភាពរបស់យើង។ អាសយដ្ឋានគឺ :
http://www.thewomens.org.au

ឬអ្នកក៏អាចសុំឲ្យអ្នកថែទាំអ្នកនៅ RWH ផ្តល់ឲ្យអ្នកនូវឯកសារបោះផ្សាយ ឬ ប័ណ្ណពត៌មានណាមួយ នៃប័ណ្ណពត៌មានអំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះផ្សេងទៀតរបស់យើងផងដែរ។ សូមសួររក :

ទី 2 ស្រោមអនាម័យ និង ស្រោម Diaphragms

ទី 3 Pill (ថ្នាំគ្រាប់)

ទី 4 Depo Provera – ការចាក់ថ្នាំបង្ការកុំឲ្យមានផ្ទៃពោះ

ទី 5 Implanon – ការវះផ្សាំបង្ការកុំឲ្យមានផ្ទៃពោះ

ទី 6 Intra Uterine Device (IUD)– (ឧបករណ៍ដាក់ក្នុងស្បូន)

***ពត៌មាននៅក្នុងប័ណ្ណពត៌មាននេះ គឺផ្អែកទៅលើប័ណ្ណពត៌មាន Basic Facts About Contraception (ហេតុការណ៍គោលការណ៍អំពីវិធីបង្ការកុំឲ្យមានផ្ទៃពោះ) ដែលផលិតដោយ FPA Health***

មិនត្រូវផលិតឡើងវិញសំរាប់គោលបំណងលក់ដូរ ដោយគ្មានការអនុញ្ញាតរបស់ FPA Health និង Royal Womenís Hospital ឡើយ។

FPA health
Leading the way in reproductive & sexual health